**BMI0095**

# សម្ភាសន៍ជាមួយឈ្មោះ ផល សឿន ភេទប្រុស អាយុ៧៨ឆ្នាំ មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានកងចាស់ៗ សព្វថ្ងៃរស់នៅភូមិម៉ៅ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ហ៊ិន សុធានី

០០:៣២:៤៨

១៦ទំព័រ

សឿន : ឪពុកខ្ញុំធ្វើផ្ទៃៗទៅគាត់បារាំងទៅច្បាំងគ្នានឹងថៃ ច្បាំងទៅចាញ់ថៃៗបានខ្ញុំទៅរៀនៗនៅវត្តផ្គាំនោះ។ ទៅរៀនវត្តផ្គាំរួច ហ្នឹងហើយបានដែលសម្តេចសីហនុនេះ តវ៉ាថយពីសៀមរាប បាត់ដំបងនេះទាំងអស់ថយចេញ។ ថយចេញទៅផុតវាដកថៃវាដក កាលនោះវារយៈរឿងរៀនណាំ ពីដើមមិញ.....រត់ទៅថៃទៅថៃមក ប៉ុន្តែថៃឆាប់ថយពេក។ ដល់ថយទៅត្រង់នេះកើត មានហៅថាឥស្សរៈមួង កើតឥស្សរៈមិនមានការកើតទេ ពីផងផងណា ហើយនេះឡប់ផ្ទាត់នេះ នែក! ឪពុកខ្ញុំមិនទាន់បានប្រពន្ធបានអីនៅតែកំលោះ។ ឫស្សីពីផងផងខ្លាចបារាំងទៅហាត់នៅ ភ្នំព្រះ។

ធានី : ម៉េចទៀតតា?

សឿន : ដល់ធ្លាប់នៅភ្នំព្រះត្រង់នេះវាកើតឥស្សរៈវាមិនទាន់ដល់ កើតឥស្សរៈត្រង់នេះទៅចាញ់អារឿងផុតឥស្សរៈហើយ ត្រង់នេះកើតមានខ្មែរសេរី ខ្មែរក្រហម ចេញមកពីខាងថៃនោះឯង ចេញពីខ្មែរសេរីរួចឡើងខ្មែរក្រហម។ ចេញពីក្រហមកើតយៀកកុង ក៏ខ្មែរយើងរត់មួងទៀត ខាងនេះក៏មកធ្លាក់ច្រើនដងហើយ ដល់នេះទៀត។

ធានី : ទៅដល់ណាតា?

សឿន : ទេ! ដល់នែក!កើតខ្មែរសេរីរួច ឈប់ខ្មែរសេរី រួចក៏ចូលខ្មែរក្រហម ផុតខ្មែរក្រហមនេះទៅនែក!ហៅថាខ្មែររំដោះ ឯងមិនសួរចាំបាន។ ហើយបានវាមានយៀកកុងអីមកតគ្នាៗ នែក! កាលនោះហៅនែក!ខាងអាមេរិចស្អី។ ធ្វើដល់ទ័ពខ្មែរក្រហម តស៊ូចាញ់ៗខ្មែរក្រហមទៅនៅកាលលន់ នល់ ដល់សម័យក្រោយ។ សម័យកាប៉ុលហោះទម្លាក់ រួចគេឲ្យរើផ្ទះរើសម្បែងរើអីទៅ ចាញ់ខ្មែរក្រហមនៅលើទឹកថាបង្កើតបានសព្វថ្ងៃថាបានដែរ ចេញខ្មែរក្រហមរួចចប់អាហ្នឹងម៉ាវគ្គហើយណា។ ខ្មែរក្រហមនេះកើតច្បាំងចាញ់យួនថាចោះ ចាញ់យួនកើតខ្មែរ

ក្រហមផង នែក! ប៉ារ៉ាផង ជួយគក្នាដេញយួនចេញពីប្រទេសខ្មែរ ។ នេះដល់យួនគេដកថយ ទៅផុតហើយត្រង់នេះក៏នៅតែចូលមកយើងសព្វថ្ងៃបានជាប់ហ៊ុនសែន ជាប់ធ្វើសព្វថ្ងៃ ។ មាន អីប៉ុននោះឯង ចប់គ្រាន់តែនិយាយដឹងគោលៗតិចៗ ប្រវត្តិសាស្ត្រ ប៉ុននោះដឹងតើ ។

ធានី ៖ ចឹងសុំ លោកតាៗមានឈ្មោះអីដែរ?

សឿន ៖ បាទ! ផល សឿន ។

ធានី ៖ ផល សឿន?

សឿន ៖ បាទ!

ធានី ៖ ផល សឿន ឆ្នាំហ្នឹងលោកតាអាយុប៉ុន្មានហើយ?

សឿន ៖ អាយុ៧៨ ។

ធានី ៖ លោកតាមានស្រុកកំណើតនៅណា?

សឿន ៖ ស្រុកកំណើតនេះឯង ។

ធានី ៖ នៅភូមិឃុំអីដែរ?

សឿន ៖ អឺ! ភូមិថ្កាំ ស្រុកស្វាយចេក ។

ធានី ៖ ភូមិថ្កាំ ឬក៏មួយក៏ ភូមិ?

សឿន ៖ ឃុំថ្កាំ ភូមិម៉ៅ អានេះភូមិម៉ៅ ។

ធានី ៖ ចឹងភូមិម៉ៅហ្នឹងមានយូរហើយ?

សឿន ៖ បាទ! មកយូរហើយ ចាប់ពីស្រុកនេះ ។

ធានី ៖ ចឹងភូមិម៉ៅ ឃុំថ្កាំ ស្រុកស្វាយចេក?

សឿន ៖ បាទ! ស្រុកស្វាយចេក ពីដើមមិញបានថៃហៅខាន់ ។

ធានី ៖ ហៅខាន់?

សឿន ៖ ខាន់ស្វាយចេក ។

ធានី ៖ ចឹងលោកតា ចឹងភូមិម៉ៅហ្នឹងមានយូរហើយ?

សឿន ៖ បាទ! មានយូរហើយ ។

ធានី ៖ ចឹងលោកតាដឹងប្រវត្តិភូមិម៉ៅហ្នឹងម៉េចទេ ពីមុនមក?

សឿន ៖ បាទ! ប្រវត្តិសាស្ត្រខ្ញុំកើតមិនទាន់ទេ ។

ធានី ៖ អត់ដឹងថាប្រវត្តិម៉េចទេៗ?

សឿន ៖ បាទ! ប៉ុនប្រវត្តិពីដើមមិញវានៅនោះ មានគោកចាស់ស្រះនៅនោះ ដល់វាចែដន្យមកកើតជម្ងឺចុកពោះក៏បែកសំបុកគ្នា បែរមកនៅខាងនេះ បានជាដល់សព្វថ្ងៃ ។

ធានី ៖ ម៉េចបានគេដាក់ឈ្មោះភូមិហ្នឹងឈ្មោះម៉ៅចឹង?

សឿន ៖ ឮថាតាម៉ៅជាំស្រូវ ពីដើមមិញយកនាមនោះឯង ទើបបានកាលទៅថៃវាចែកគ្នាយានវេនៗ យកទឹកត្រពាំងភូមិម៉ៅ ។ ចឹងតាម៉ៅៗគាត់នៅនេះឯង ដល់គាត់ចែកដល់ថៃ កាលមុនគេវាស់ចែកគ្នា កាលម៉ាចំនួនឯងនេះគេចែក......ខាងជើងសាលាដំណាក់កកោះ ត្រពាំងវាលតូចមក នេះស្រុកម៉ៅ ទៅនោះស្រុក ។

ធានី ៖ ម៉ៅហ្នឹង មកពីតាម៉ៅហ្នឹងគាត់ធ្វើអីគេនៅភូមិយើង?

សឿន ៖ បាទ! គាត់ធ្វើស្រែពីដើមមិញ ធ្វើស្រែចំការ ជាប់នោះឯង ។

ធានី ៖ តាម៉ៅធ្វើស្រែច្រើនលោកតា?

សឿន ៖ បាទ!

ធានី ៖ ប៉ុន្មានហិចតា លោកតាដឹងទេ កាលហ្នឹង?

សឿន ៖ អានេះខ្ញុំមិនដឹងប្រវត្តិសាស្ត្រទេ ដឹងតែប៉ុននោះឯង ។

ធានី ៖ ចា៎! ដឹងថាតាម៉ៅធ្វើស្រែនៅហ្នឹងច្រើនជាងគេ?

សឿន ៖ នោះហើយ ដល់តែដឹងៗមិនទាន់សព្វគ្រប់ផង គ្រាន់ថាត្រួសៗបានម៉ាតិចៗ ។ ប៉ុននោះឯងខ្ញុំដឹងច្រើន ដឹងបានរស់សព្វថ្ងៃចឹង ។

ធានី ៖ ឪពុកលោកតាឈ្មោះអីគេ?

សឿន ៖ ឪពុកឈ្មោះ ផល សៀង ។

ធានី ៖ អីគេ?

សឿន ៖ ឪពុកខ្ញុំឈ្មោះផល តាឈ្មោះសៀង ។ ពីដើមមិញគេហៅតាម ណាំស្រក្ហួន ផលសៀង ណាក់ចេះគេហៅណាំស្រក្ហួន បើយើងសព្វថ្ងៃហៅនេះ ណាស្ដីមើលដែលភ្លេច ថៃហៅណាំស្រក្ហួន ។ សព្វថ្ងៃ........(និយាយថៃ) ។

ធានី ៖ អូ! លោកតាចេះថៃច្រើន?

សឿន ៖ ទេ! មិនចេះច្រើនទេ ចេះតិចៗ គ្រាន់តែបកប្រែគ្នាតិចៗបាន ។

ធានី ៖ ចឹងលោកតាឈ្មោះ ផល សឿន?

សឿន ៖ បាទ!

ធានី ៖ ដល់ពេលឪពុកលោកតាឈ្មោះ សឿន ផល?

សឿន ៖ បាទ! មិនមែនសឿន ផល ផល សឿន ។

ធានី ៖ លោកតាឈ្មោះផល សឿន ចុះឪពុកលោកតាឈ្មោះ?

សឿន ៖ នែក! សៀង ផល ។

ធានី ៖ សៀង?

សឿន ៖ សៀង ផល នោះហើយ ។

ធានី ៖ សៀង ផល គាត់ស្លាប់ពេលណាលោកតា?

សឿន ៖ អូ! អារឿងស្លាប់ចាំមិនបានទេ ភ្លេចហើយ ។

ធានី ៖ ចុះម្តាយលោកតាឈ្មោះអីគេ?

សឿន ៖ ម្តាយខាងម៉ែនោះ អានោះឈ្មោះ ហ៊ុន ។

ធានី ៖ អីគេហ៊ុន?

សឿន ៖ ហ៊ុន យស់ ។

ធានី ៖ ហ៊ុន យស់?

សឿន ៖ បាទ!

ធានី ៖ គាត់ស្លាប់ពេលណាលោកតា?

សឿន ៖ ស្លាប់នោះ ដុតចោលអស់ហើយ វានៅ...។

ធានី ៖ ឆ្នាំប៉ុន្មាន មានដឹងទេ?

សឿន ៖ វាមិនចាំទេ ។

ធានី ៖ យូរហើយ?

សឿន ៖ យូរហើយ ។

ធានី ៖ កាលហ្នឹងលោកតាអាយុប៉ុន្មាន?

សឿន ៖ កាលពេល ខ្ញុំបានប្រពន្ធមិនថាយូរប៉ុន្មាន បានប្រពន្ធកូនឡើងហៅកូននៅតូចៗហើយចុះ ចៅប៉ុននាងឯងហើយ ។

ធានី ៖ ចឹងលោកតាមានបងប្អូនប៉ុន្មាននាក់?

សឿន ៖ ខ្ញុំបងប្អូនតែ៤នាក់ប៉ុននោះ ។

ធានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សឿន ៖ ងាប់កាលបដិវត្តនេះ ងាប់២នាក់ នៅតែ២នាក់ អ៊ុំដូន ខ្ញុំប៉ុននោះ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សឿន ៖ គ្មានស្រីម៉ាកមួយទេ។

ធានី ៖ ស្រី១ ប្រុស៣?

សឿន ៖ ប្រុស៤។

ធានី ៖ ប្រុស៤ ស្រី១?

សឿន ៖ មិនមានស្រីទេ។

ធានី ៖ អត់មានស្រីទេ?

សឿន ៖ អឺ! អា២ក៏ប្រុស។

ធានី ៖ ដល់ពេលស្លាប់២សម័យបដិវត្តហ្នឹង ប្រុសដែរ?

សឿន ៖ អឺ! សម័យងាប់២ សម័យបដិវត្ត។

ធានី ៖ អត់មានស្រី?

សឿន ៖ មិនមានស្រីម៉ាក់មួយទេ។

ធានី ៖ សម័យបដិវត្ត ឆ្នាំប៉ុន្មាន តាដឹងទេ?

សឿន ៖ អានោះខ្ញុំមិនសូវចាំ ខ្ញុំមិនសូវចាំទេ។

ធានី ៖ បដិវត្តខ្មែរក្រហមយើងហ្នឹងមិនមែន?

សឿន ៖ នោះហើយ វាមិនបានដែលនៅយូរមិនសូវចាំទេ។

ធានី ៖ ហើយគ្រួសារលោកតាឈ្មោះអីគេ គ្រួសារប្រពន្ធលោកឈ្មោះអី?

សឿន ៖ នែក! ភឹក ងាប់ហើយណា៎។

ធានី ៖ ចា៎!ឈ្មោះអីគេ?

សឿន ៖ ភឹក យ៉ុង។

ធានី ៖ ភឹក យ៉ុង?

សឿន ៖ បាទ! នេះគ្រួសារដើម គ្រួសារសព្វថ្ងៃមិនមែនទេ។

ធានី ៖ ចា៎! ភឹក យ៉ុងនឹងស្លាប់ពេលណា?

សឿន ៖ ស្លាប់កាលសម័យខ្មែរក្រហម អឺ!នែក!យួនចូល។

ធានី ៖ យួនចូលមក១៩៧៩?

សឿន ៖ ហ្នឹងហើយ។

ធានី ៖ ដោយសារអីគេ គាត់ស្លាប់?

សឿន ៖ ដោយសារវាមិនមានពេទ្យ កើតរបេង នោះហើយវាមិនមានពេទ្យ ទៅនោះទៅវិញរួច នោះ វាមិនកើតកុំអីក៏វាមិនទាន់ងាប់ ។

ធានី ៖ លោកតាមានកូនប៉ុន្មាននាក់?

សឿន ៖ ដែលខ្ញុំនេះ កូនឡើង១០ ។

ធានី ៖ កូន១០ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សឿន ៖ ស្រី៧ ប្រុស៣ ទើបងាប់មួយឆ្នាំទៅមិញ ស្រីបងគេ ។

ធានី ៖ ដោយសារអីគេ ស្លាប់ដោយសារអីគេ?

សឿន ៖ ដែលថារីករ៉ៃហើយ មានទៅហើយ មានពេទ្យទៅហើយ ម៉េចនៅតែងាប់លើពេទ្យ ។

ធានី ៖ គាត់ឈឺអីគេ?

សឿន ៖ វាក្អកខេះៗ ទៅដេកពេទ្យខាងអ៊ីដាងនោះ មកវិញជាហើយ មកវិញនេះទៀត មើលបាន អស់តែប្រាក់ នេះឯងស្រី៧ ប្រុស៣ ។

ធានី ៖ ចឹងមុនលោកតាថា ឪពុកលោកតាធ្វើអីគេ?

សឿន ៖ ធ្វើថ្នែ ។

ធានី ៖ ថ្នែហ្នឹងអីគេ?

សឿន ៖ ថ្នែរបស់យើងមេភូមិ បើបារាំងគេហៅជំទុកចេះណា ។

ធានី ៖ ធ្វើមេភូមិ?

សឿន ៖ ហ្នឹងហើយ ។

ធានី ៖ មេភូមិនៅណា?

សឿន ៖ ភូមិនៅភូមិនេះឯង ។

ធានី ៖ ភូមិម៉ោហ្នឹង?

សឿន ៖ ម៉ោយើង មេភូមិមិននេះទេ បើយើងថាសព្វថ្ងៃមើលទៅដឹងសព្វថ្ងៃអីចុះ ។

ធានី ៖ ចឹងឪពុកលោកធ្វើមេភូមិតាំងពីពេលណាមក?

សឿន ៖ វាមិនថាធ្វើមេភូមិថាធ្វើថ្នែ ថៃ....... ។

ធានី ៖ ចឹងគាត់ថៃៗ ឬខែ?

សឿន ៖ ថៃគេមកបង្រៀន គេកាន់ក្តាប់សៀមរាប បាត់ដំបងនេះណា ។

ធានី ៖ កាលសម័យបារាំងចឹង?

សឿន ៖ អានោះឯងថៃច្បាំងហ្នឹងបារាំង ។

ធានី ៖ បន្ទាប់មកទៀត ក្រោយពីហើយបន្ទាប់មកទៀត លោកតាថាឪពុកលោកតាហ្នឹងបានចូលខ្មែរឥស្សរៈទៅ?

សឿន ៖ មិនបាននេះទេ កាលឈប់នេះមកបានធ្វើអីទេ ធ្វើតែផ្លែរួចថៃថយឈប់សម្រាកខាងនេះគេមានកម្មាការកម្មអីគេឯណាគ្នាច្រើន។ នោះហើយបាននិយាយមិនទាន់ត្រឹមត្រូវអស់ទេ ខ្ញុំថាមិនទាន់ត្រូវអស់ទេថាចុះ ដែលមានខុសខ្លះត្រូវខ្លះ។ បើចង់និយាយត្រូវគ្នា បើចាំសួរចាស់ៗទាំងអស់គ្នាដូចតាជូន បងខ្ញុំបង្កើតណា។

ធានី ៖ ចឹងចង់សួរលោកតាថា លោកតាបានចូលខ្មែរក្រហមអត់ ចូលបដិវត្តអត់?

សឿន ៖ ចូល។

ធានី ៖ ចូលឆ្នាំប៉ុន្មាន?

សឿន ៖ កាលដែលចូលនោះវាយូរទៅទៀត វាភ្លេចនោះ មិនដឹងឆ្នាំប៉ុន្មាន កាលដែលចូលមើលលោកសុនហេងអីណា។

ធានី ៖ ហ្នឹងហើយមានសុន ហេង មានអី?

សឿន ៖ នោះហើយសម័យលន់ នល់។

ធានី ៖ សម័យ៦០ ហើយ៧០ជាងកាលនឹងលន់ នល់បែកឥឡូវ?

សឿន ៖ នោះឯងសម័យលន់ នល់។

ធានី ៖ សម័យលន់ នល់?

សឿន ៖ នោះឯង។

ធានី ៖ ពេលដែលលន់ នល់ឈ្នះ ធ្វើរដ្ឋប្រហារហ្នឹង?

សឿន ៖ អឺ!ដែលរដ្ឋប្រហារ។

ធានី ៖ ចឹងលោកតាចូលបដិវត្តឆ្នាំ១៩៧០?

សឿន ៖ អឺ!នោះឯងចូល។

ធានី ៖ ឆ្នាំ១៩៧០ចូលបដិវត្ត ចូកបដិវត្តនៅកន្លែងណា?

សឿន ៖ បដិវត្តនោះ។

ធានី ៖ ហ្នឹងហើយចូលនៅកន្លែងណា?

សឿន ៖ បដិវត្តនោះ ទេ!នៅតែកន្លែងនេះ ប៉ុនកន្លែងនេះធ្វើទាហាន។

ធានី ៖ ហើយសុនហេងអ្នកដឹកនាំ ឬក៏ម៉េច?

សឿន ៖ កាលនោះស៊ិនសេន ពួកខាងនេះគេថា ខ្មែរក្រហមគេថាអាហេងជាប្រមុខមិនទុកច្រះប្រាំបាយ កាលនោះគេ កាលនេះគេបានហើយរត់ចេញអស់។ ដល់បានហើយគេឲ្យឯងធ្វើទាហានខ្មែរក្រហមចេះ។

ធានី ៖ លោកតា?

សឿន ៖ អឺ! គ្រាន់តែកាន់ក្ដាប់។

ធានី ៖ ក្ដាប់ខាងអីគេ?

សឿន ៖ ក្ដាប់ខាងចំការ។

ធានី ៖ ខាងចំការម៉េចលោកតា?

សឿន ៖ ធ្វើចំការចេះ គ្នាច្រើន គេរើសយកមេពួកមួយ។

ធានី ៖ ចឹងលោកតាធ្វើប្រធានអ្នកក្ដាប់ចំការ ធ្វើចំការហ្នឹង?

សឿន ៖ អឺ!ក្ដាប់ចំការ។

ធានី ៖ មនុស្សប៉ុន្មានរយនាក់ទៅ?

សឿន ៖ ទេ! ដែលក្ដាប់នោះ មិនមែនក្ដាប់មនុស្សចាស់ទេ អាផ្នែកខាងគេខាងគេខាងតាជូនក្ដាប់យុវជន។

ធានី ៖ អូ! លោកតាខាងមនុស្សចាស់?

សឿន ៖ អឺ!ខាងចាស់ៗ។

ធានី ៖ ចាស់ៗប៉ុន្មានរយនាក់?

សឿន ៖ ចាស់ៗ៨-១០នាក់ គាត់ជម្លៀសតាមចំការ ជម្លៀសដែលអានេះហើយ។

ធានី ៖ នៅភូមិយើង?

សឿន ៖ នៅភូមិយើង អត់បានដាំដំឡូងទេ គេអ្នកដាំគឺគេក្មេងៗ ឯងខាងចំការដាំថ្នាំផងដែលយ៉ាប់ហាន់ថ្នាំ។

ធានី ៖ ហាន់ថ្នាំ?

សឿន ៖ អឺ! ថ្នាំជក់យើងចេះ។

ធានី ៖ លោកតា ដាំថ្នាំជក់ ហើយដាំថ្នាំជក់ដែរ?

សឿន ៖ ទៅដាំថ្នាំផង។

ធានី ៖ ធ្វើតែអាហ្នឹងម៉ាមុខទេ?

សឿន ៖ អឺ! ២មុខ និងដាំត្រសក់ ឪឡឹក។

ធានី ៖ ដាំបន្លែ?

សឿន ៖ អឺ!ដាំបន្លែបន្ការ ហើយខ្ញុំក្តាប់គាត់ហៅជម្លៀសនោះអីទៅ ។

ធានី ៖ ហើយអ្នកណាគេ អ្នកឲ្យលោកតាធ្វើការងារអស់ហ្នឹង អ្នកណាចាត់តាំងឲ្យលោកតាធ្វើ?

សឿន ៖ ទេ! គ្រាន់តែធ្វើឲ្យកាន់ក្តាប់ ។

ធានី ៖ ហ្នឹងហើយអ្នកណាឲ្យលោកតាកាន់ក្តាប់?

សឿន ៖ នែក! ពួកខ្មែរក្រហមគេអ្នកឲ្យឯងកាន់ក្តាប់ ។

ធានី ៖ ស្គាល់ទេ លោកតា?

សឿន ៖ អ្នកណា?

ធានី ៖ អ្នកដែលឲ្យលោកតាកាន់ក្តាប់?

សឿន ៖ អូ! ងាប់អស់ ចុះដឹងឈ្មោះ តាមឿន ។

ធានី ៖ តាមឿនជាអ្នកណា?

សឿន ៖ តាមឿនហ្នឹងគេអ្នកកើត នោះហើយគេអ្នកខ្មែរក្រហម គេកាន់ក្តាប់កង ងាប់ហើយងាប់កាល ធ្វើបុណ្យនេះកាលលើកអាងត្រពាំងថ្ម ។

ធានី ៖ អាងត្រពាំងថ្ម?

សឿន ៖ នោះហើយ ។

ធានី ៖ ឈ្មោះ តាមឿង?

សឿន ៖ អឺ!

ធានី ៖ តាមឿនហ្នឹងប្រធានសហករណ៍ ឬក៏ប្រធាន?

សឿន ៖ ប្រធានសហករណ៍ទាំងអស់ គាត់កាន់ក្តាប់ណា ។

ធានី ៖ ប្រធានសហករណ៍នៅតាម៉ៅហ្នឹង?

សឿន ៖ នៅម៉ៅជជង ទៅចេះជង គាត់ទៅចាក់...នោះហើយ ។

ធានី ៖ ចុះអ្នកណាគេប្រធានតំបន់លោកតាដឹងទេ?

សឿន ៖ តំបន់នោះមិនដឹងទេ ប៉ុនតំបន់នៅផ្លូវស្វាយ កាលតំបន់ហ្នឹង ភូមិយើងជម្លៀស...គេឲ្យទៅនៅ រើផ្ទះឯស្វាយនោះ បានគេហៅ ។

ធានី ៖ ចុះលោកតាបានចូលរួមរើផ្ទះហ្នឹងគេនៅស្វាយ?

សឿន ៖ បាទ! ទៅឯងនៅក្មេង យើងចេះប្រើ២នាក់ទៅ ទៅរើផ្ទះគេឡើងអស់គ្រាន់ ។

ធានី ៖ តាមឿនហ្នឹង ថ្មីបានស្លាប់នៅពេលលើកទំនប់នៅអាងត្រពាំងថ្ម?

សឿន ៖ ទេ! តាមឿនក្រោយគាត់ផ្លាស់ទៅនោះ គាត់ទៅនៅត្រពាំងថ្ម កាលក្តាប់បានអីនេះធំតិច អ្នកបានគាត់ច្រឡំសម្លាប់មិនដឹង.......។ ច្រើនណាស់...... និយាយរឿងសព្វថ្ងៃ អាមួយ.........ចុះគេអ្នករៀនៗ ដល់សៀមរាបបាត់ដំបង បានថាកូនចៅថៃ ថា....................(និយាយភាសាមិនអាចស្តាប់បាន) ។ អាហ្នឹងកាលដែលបានមកគេចុះឯង អានេះគេមានក្រោយបានកាលសម្តេចសីហនុ...សព្វថ្ងៃ ដីបានមកក្រោយគេតើបានៗមក ។

ធានី ៖ ចឹងលោកតាមិញលោកថា តាមឿនហ្នឹងគាត់ធ្វើប្រធានសហករណ៍នៅតាម៉ៅ ហើយបន្ទាប់មកទៀត?

សឿន ៖ ទេ!............(ស្តាប់មិនបាន) ។

ធានី ៖ ក្រោយមកតាមឿនទៅ អ្នកណាគេជំនួសគាត់?

សឿន ៖ មិនមានទេលើក ។

ធានី ៖ ចុះក្រែងលោកតាថាតាមឿនស្លាប់នៅត្រពាំងថ្ម?

សឿន ៖ អឺ! ស្លាប់នោះហើយ ។

ធានី ៖ ចុះបានអ្នកណាគេគ្រប់គ្រងលោកតាបន្តទៀតនៅសហករណ៍ម៉ៅនឹង?

សឿន ៖ សហករណ៍កើតអាក្រោយនេះ សហករណ៍ភូមិយើងតិចតួចមានរោងសមូហភាព ។

ធានី ៖ ហើយអ្នកណាគេអ្នកដឹកនាំ?

សឿន ៖ មានអាត្រង់នេះមួយរើផ្ទះហ្នឹងឯង រើផ្ទះណាមួយធំប៉ុននេះ រើធ្វើសមូហភាពទៅនោះមួយៗឯងផ្ទះឯងតែធំហើយគេរើហើយ តែមិនបានរើទេ គេអ្នកធំគេមករកឯងត្រូវតែចាកចេញ ។

ធានី ៖ ចាកចេញទៅណាវិញតា?

សឿន ៖ មិញគេជម្លៀសទៅនៅតាមព្រៃអស់ យកក្តារនេះទៅរើសសមូហភាពធ្វើផ្ទះឯងត្រូវមានអីគេរើយកគ្មានបានប្រាប់យើងណា ។ យកទៅដល់ធំចឹងទៅរោងសមូហភាព ផ្ទះនេះទើបក្រោយ ។

ធានី ៖ ចុះលោកតាដឹងថាអ្នកគ្រប់គ្រងនៅហ្នឹងកាលពីមុនអ្នកណាគេអត់ នៅសម័យខ្មែរក្រហមៗលោកដឹងថាអ្នកណាគ្រប់គ្រងនៅភូមិឃុំយើង ក្រៅពីតាមឿនហ្នឹង?

សឿន ៖ គេចុះពីតាមឿនមក ត្រង់នេះបានដល់អានិរតីៗកាចណាស់វៃមនុស្សរាប់ពាន់ តែធ្លាប់មកវៃអស់មិនតិចទេ ខ្មោចវៃនឹងពូថៅ ។ និរតីមកកាន់ក្តាប់ឲ្យអានោះចេញ និរតីគេចុះមកកាន់កាប់ដឹងការចុះលើកអី គេតាំងឲ្យឯងចេញទៅនៅពាសណាពាសណែតាំងមានគត្នា ម៉េច អ្នកស្រុក

នេះឯង  អ្នកណាធ្វើមិនឲ្យគ្នានៅបានដេញគ្នា  នេះចាប់នេះនៅផាប់ពាសនោះតគ្នា  វាមានគ្រាប់  បើគ្នាវាដឹងមានប៉ុន្មាន  ប៉ុនវាសហករណ៍ធំ  នោះឯង ។

ធានី :  ហើយនិរតីហ្នឹងឈ្មោះអីគេ  លោកតាដឹងទេ?

សឿន : វាមិនបានធ្លាប់ស្គាល់ទេ  ចុះគេនិយាយតែតែឡាន់ៗដូចវាមិនសូវច្បាស់ផង ។  គេមិននៅ  ប៉ុនគេមកនៅឆ្នាំនោះ  ចុះគេគ្រាន់តែឲ្យគេមកក្តាប់យើងនេះឯង  មិនទៅផ្អើលខ្មែរក្រហមឯងណា  និរតី  ប៉ុនខ្មែរក្រហមជម្លៀសឯងទៅតាមវាលទៅនៅបន្ទាយឆ្មារនោះ ។  ទៅនៅបន្ទាយឆ្មារ  ប៉ុនបរទៅបរមកៗដូច  ទៅមិនមែនខ្មែរក្រហម  ពួកនែក!ប៉ាវ៉ា  ថាហ៎!វាប្រះស្រុកអស់ហើយ  នឹងក៏នាំឲ្យមកផ្ទះ  យួនចូលទើបដល់  ថាឲ្យអ្នកស្រុកមកវិញចុះ  ទៅនៅតាមព្រៃប្រយ័ត្នគេបន្តក់ត្រូវក៏នាំគ្នាបរទេសចូលឲ្យចូលភូមិ ។  បរមកទៅផ្ទះអ្នកណាអស់  អ្នកណារូបៗរៀងៗមកវិញទៅតាមនេះអស់ស្រុកអស់រលីង ។

ធានី :  ចុះម៉េចទៅតា  ព្រៃអី  ភូមិយើងម៉េចទៅពេលចូលមក  ពេលដែលតានិយាយ?

សឿន : ទេ!  យួនហៅវ៉ៃយកតាមព្រៃប្រយ័ត្នគេបន្តក់ត្រូវនៅតាមព្រៃ  ហៅមកទៅបានចូលបន្តាក់បានម៉ាយប់ដែរ...ខ្វះបាត់គោបាត់អី  ដាក់អន្ទង់ធំបានម៉ាយប់បានគេហៅបញ្ជូលមកនេះ  ចូលតាមភូមិ ។  នេះយួនក្រែលក្តាប់ជួបសព្វថ្ងៃថាចុះ ។

ធានី :  ចុះយួនកាន់កាប់អត់អីណា  លោកតារស់នៅហូបចុកអី?

សឿន : ទេ!  កាលយួនកាន់ក្តាប់មកអានោះមានអីទេ ។

ធានី :  រស់នៅស្រួល  ហូបចុកអីបានហើយ?

សឿន : បាទ!  មានទៅអី  មានតែដើរយ៉ាប់តែវា ។

ធានី :  យ៉ាប់វាម៉េច?

សឿន : វាប៉ុនលួចមាន់ស្រុកយកទៅ ។

ធានី :  យួនលួចមាន់?

សឿន : លួច ។

ធានី :  ក្រៅពីហ្នឹងអត់មានអីលោកតានោះ?

សឿន : វាមានកាំភ្លើងអី ។

ធានី :  និយាយចឹងបន្ទាប់ពីយួនមកទៀត  មានខាងណាខាងណៃគេមកវ៉ៃអីនៅភូមិយើង?

សឿន : បាទ!  មានប៉ាវ៉ាខ្មែរក្រហម ។

ធានី :  ប៉ាវ៉ាខ្មែរក្រហមមកវ៉ៃភូមិយើងទៀត?

សឿន ៖ រ៉ែភូមិនេះរ៉ែ អាងាប់គ្រាប់យើងបន្តក់ត្រូវរត់នាំគ្នារត់ឡើង ។

ធានី ៖ ចឹងអ្នកភូមិយើងរត់ចុះរត់ឡើងរហូតលោកតា?

សឿន ៖ អូ! រត់គ្នាបានបណ្តាក់ទេ ។

ធានី ៖ រត់ទៅណាខ្លះទៅ?

សឿន ៖ បាទ! រត់ទៅពីដើមមិញព្រៃព្រលាន ចេញពីព្រៃព្រលានរួចទៅនេះបានទៅនោះស្រុកទ្រាស ចេញពីស្រុកទ្រាសទៅនៅស្រុកកំពង់ថ្មី ចេញពីកំពង់ថ្មីបានទៅថ្មពួក ចេញពីថ្មពួកទៅនៅថ្នល់ដាច់.........ឲ្យមកវិញៗស្រាប់មកនៅអន្លង់ធំ ភូមិខ្មែរក្រហមចូល អឺ!ប៉ារ៉ាចូលមក អឺ!យួនចូលមកគេថាឲ្យនិយាយចប់គ្នា ។

ធានី ៖ ចឹងបាននៅចឹងពេលណាដែលយើងឈប់រត់ឈប់អី ឈប់លេងក្នុងសង្គ្រាមឈប់មានអីទាំងអស់ លោកតា ដឹងឆ្នាំប៉ុន្មានទេ?

សឿន ៖ មិនដឹងឆ្នាំទេ បើឆ្នាំចាំសួរគេទៅគេដឹង មិនសូវចាំ ។

ធានី ៖ អត់សូវចាំ?

សឿន ៖ នោះហើយ បានយើងចូល ។

ធានី ៖ គ្រាប់ដឹងថាក្រោយមកទៀតបានសន្តិភាពរហូតបានដល់សព្វថ្ងៃ?

សឿន ៖ ហ្នឹងហើយសន្តិភាព ។

ធានី ៖ លោកតាយល់ម៉េចដែរ ចំពោះការរស់នៅដូចថាពីមុនមកដល់ឥឡូវ វាមានភាពខុសគ្នាយ៉ាងម៉េច?

សឿន ៖ ទេ! អត់មានម៉េច មានអីយើងរកដូចការយើងរៀនសូត្រគ្នាចេះ ទាល់តែមានគេច្បាំង អាហ្នឹងមុនដំបូងណានោះ គេមានចម្បាងថាគេឲ្យយើងចេញក៏ចេញរត់ កាលសាធារណរដ្ឋ កាលលន់ នល់ រដ្ឋប្រហារនោះឯងបែកបាក់គ្នាត្រឹមនោះច្រើនណាស់ ។

ធានី ៖ លោកតាមានស្គាល់ឈ្មោះមេដឹកនាំខ្មែរក្រហមផ្សេងទៀតទេ?

សឿន ៖ ទេ! ស្គាល់ទៅគេស្គាល់ ។

ធានី ៖ ចុះក្រៅពីស៊ុន?

សឿន ៖ ស្គាល់តែតាមឿនមួយដែលងាប់ ។

ធានី ៖ ចុះលោកតាដែលថាមាននេះ?

សឿន ៖ .....

ធានី ៖ ចា៎! ហ្នឹងហើយក្រៅពីគាត់ហ្នឹងមានអ្នកផ្សេងទៀតទេ?

សឿន ៖ មុនមិនធ្លាប់ស្គាល់គេអ្នកក្រៅៗផង គេមិនសួរដែលឲ្យទៅណាទេ ។

ធានី ៖ ចុះសុន ហេងអីនោះ?

សឿន ៖ ទេ! ខាងសុនហេង ខាងលន់ នល់ ។

ធានី ៖ សុន ហេងហ្នឹង?

សឿន ៖ ហ្នឹងហើយ ខាងលន់ នល់ គេរដ្ឋប្រហាររួចបានគេកាន់ក្តាប់ ដល់ច្បាំងចាញ់គេទៅ លន់ នល់ អីគេរត់ទាំងអស់នោះ នៅតាមគ្នានោះ ។

ធានី ៖ ចុះលោកតារៀបការឆ្នាំប៉ុន្មាន?

សឿន ៖ នោះឯងវាមិនចាំ ។

ធានី ៖ អត់ចាំទេ?

សឿន ៖ បានគេអ្នកធ្វើប្រធានភូមិសព្វថ្ងៃមានចេះ ។

ធានី ៖ មានប្រធានភូមិរាល់ថ្ងៃ គាត់នៅណាវិញផ្ទះគាត់?

សឿន ៖ នៅនេះឯង ផ្ទះគាត់ ។

ធានី ៖ ជាប់ផ្ទះប្រធានមេក្រុមប្រឹក្សាឃុំហ្នឹង?

សឿន ៖ អឺ!នោះឯងទៅនោះ ។

ធានី ៖ គាត់ឈ្មោះអីគេ?

សឿន ៖ សព្វថ្ងៃគេឈប់ធ្វើហើយមេភូមិណា៎ ។

ធានី ៖ ចា៎! ប៉ុន្តែគាត់ឈ្មោះអីគេ?

សឿន ៖ គេធ្វើលើពីនោះទៀត ។

ធានី ៖ ចា៎! គាត់ឈ្មោះអីគេ?

សឿន ៖ ទូច មឿន ។

ធានី ៖ សុះ មឿន?

សឿន ៖ ទូច មឿន ។

ធានី ៖ ទូច មឿន?

សឿន ៖ ហ្នឹងហើយ ។ សព្វថ្ងៃមិនបានសួរផង ។

ធានី ៖ ចឹងទូច មឿនហ្នឹងគាត់ធ្វើមេឃុំពីមុនមក?

សឿន ៖ ធ្វើជាប់ពីមុនមក ។

ធានី ៖ តាំងពីសម័យខ្មែរក្រហមក៏ធ្វើដែរ?

សឿន ៖ ទេ! កាលនោះនៅឲ្យតែហ៊ានដាក់ អ្នកណាធ្វើមេភូមិអ្នកណាម៉េចហ៊ានធ្វើ ។

ធានី ៖ ចឹងកាលសម័យខ្មែរក្រហមអត់មានអ្នកណាធ្វើ?

សឿន ៖ បើធ្វើធំគេខ្មែរក្រហមកិននោះឯង គ្រាន់ថាឲ្យរៀបគ្រួសារដើររៀបសុំគ្នាឯង ។

ធានី ៖ ប៉ុន្តែកាលហ្នឹងលោកតា ទូច មឿនហ្នឹងគាត់?

សឿន ៖ នែក! ដើរៗធ្វើទៅ អាទូចមានអី លើគេ ទៅបៀតគេចេះគ្រាន់ បានវាកាន់ក្ដាប់ ។

ធានី ៖ កាន់ក្ដាប់អ្នកភូមិយើង?

សឿន ៖ អឺ!ចុះកាន់ក្ដាប់អ្នកភូមិយើង ដល់គេឲ្យពីសម័យគេឈប់ធ្វើបានរើសសព្វថ្ងៃ ។

ធានី ៖ មិនមែនទេ ចង់សួរថាទូច មឿនហ្នឹង គាត់ធ្វើជាមេឃុំតាំងពីសម័យខ្មែរក្រហមមក ឬក៏សព្វថ្ងៃ?

សឿន ៖ ទេៗ សម័យខ្មែរក្រហមមិនមានទេ ។

ធានី ៖ សម័យខ្មែរក្រហមគាត់ធ្វើអីគេវិញ?

សឿន ៖ ទេ! ធ្វើរាស្ត្រដូចជាយើងចឹង ប៉ុនគ្រាន់ថាយូរៗគេមកឲ្យឯងមួង ម្នាក់មួងចេះ ។

ធានី ៖ ចុះអត់ដឹងថាគាត់ធ្វើអីសម័យខ្មែរក្រហម?

សឿន ៖ ទេ!ខាង ។

ធានី ៖ ដូចលោកតាចឹងអ្នកដាំបន្លែ?

សឿន ៖ ខាងគេអ្នកដាំបន្លែដាំអីគេអ្នកក្មេងៗ អាហ្នឹងខាងជំនាញកាប់អីណ៎ ។

ធានី ៖ មិនមែនប្រធានអីទេ?

សឿន ៖ ទេ! មិនមានទេ មានតែគេប្រធានចាំតែគេហៅ ។

ធានី ៖ ចុះលោកតាមានស្គាល់អ្នកផ្សេងទេ ដូចថាធ្វើនៅសម័យខ្មែរក្រហម ជាអ្នកដឹកនាំគេម្នាក់ដូចលោកតាចឹង ធ្វើជាប្រធានខាងដាំបន្លែ អ្នកផ្សេងដូចថាផ្ទះបាយ ខាងអីចឹងមានទេលោកតានៅភូមិយើងមានទេ?

សឿន ៖ ពួកនោះទៅអស់ កាលដែលទម្លាក់ដែលគេកាលគេពួកឯងទៅ គេដេញអ្នកភ្នំពេញមកណ៎ដែលគេ ។

ធានី ៖ ចា៎! ខាងណាគេ?

សឿន ៖ គេជម្រុះមកនៅតាមនេះឯង ក៏នៅជាប់ហ្នឹង ក៏គេអ្នកកាន់ក្ដាប់ដាំបាយអី បបរបាយ ។

ធានី ៖ ចា៎! ស្គាល់នៅភូមិយើងមានទេ?

សឿន ៖ ងាប់អស់ហើយ មិនមែនភូមិយើងទេ ភូមិគេប៉ុនងាប់អស់ហើយ ។

ធានី ៖ អត់មានអ្នកនៅភូមិយើងអ្នកធ្វើការងាររស់ហ្នឹង?

សឿន ៖ ទេ! គេអ្នកកាន់ក្តាប់ ។

ធានី ៖ តែទូច មឿនហ្នឹងគាត់ជា?

សឿន ៖ ហ្នឹងហើយ គាត់មុនគេបង្អស់ តាមឿនៗ ។

ធានី ៖ មិនមែនតាមឿនប្រធានសហករណ៍ហ្នឹងណា?

សឿន ៖ នោះគាត់នៅណានៅកើតនោះ មិនដឹងទេគ្រាន់ ។

ធានី ៖ ចឹងទូច មឿននេះគាត់?

សឿន ៖ គាត់វែដល់ណា គាត់ឈរត្រឹមនោះៗ ដឹងគេមកដល់នេះទាល់ហើយថយទៅវិញ ថយទៅនៅស្រុក..... បានខ្មែរក្រហមហើយមានអីទៅលើកទំនប់ប្រឡាយ មានបានឲ្យទៅឈរលើកនេះណា សុទ្ធតែថ្ម ទំនប់ប្រឡាយណាំខាងក្រោមនោះ ។ ត្រពាំងថ្មនោះគាត់ស្រុក ប្រឡាយកាន់ក្តាប់ខាងនែកនេះណា អ្នកស្តោះព្រោះ ។

ធានី ៖ តាមឿនហ្នឹង?

សឿន ៖ អឺ! តាមឿនកាន់ក្តាប់នោះហើយ ។

ធានី ៖ ចង់សួរលោកតាថា រឿងរ៉ាវដែលលោកតាប្រាប់មិញហ្នឹង តើចៅអនុញ្ញាតិសម្រាប់យកទៅធ្វើជាសៀវភៅក៏ដូចជាសម្រាប់ក្មេងៗ ឬអ្នកសិក្សាស្រាវជ្រាវផ្សេងទៀតយកមកប្រើប្រាស់ បានទេ?

សឿន ៖ ទេ! មិនដែលបានដើរ ។

ធានី ៖ អត់ទេ អនុញ្ញាតិឲ្យខ្ញុំ អ្វីដែលលោកតាប្រាប់ហ្នឹង ពួកខ្ញុំយករឿងរ៉ាវដែលលោកតានិយាយទាំងប៉ុន្មានៗមិញប្រាប់ខ្ញុំ យកទៅសរសេរជាសៀវភៅ ទុកជាប្រវត្តិសាស្ត្រ ហើយឲ្យក្មេងៗ

សឿន ៖ ក្រែងចាំវាមិនអស់ ។

ធានី ៖ ចាំ! អត់អីទេ គ្រាន់តែចង់ឲ្យលោកតាអនុញ្ញាតិថា ។

សឿន ៖ និយាយអានោះក្លេចអានេះ និយាយអានេះទៅ ។

ធានី ៖ ចាំ! អត់អីទេលោកតា គ្រាន់តែចៅសុំការអនុញ្ញាតិពីលោកតាសិន បើលោកតាអនុញ្ញាតិឲ្យខ្ញុំយកទៅប្រើប្រាស់អីអត់ ។ អីចឹង?

សឿន ៖ យកសៀវភៅ ។

ធានី ៖ ចាំ! ធ្វើជាសៀវភៅធ្វើជាអីចឹង បើលោកតាអនុញ្ញាតិពួកខ្ញុំយកទៅធ្វើចឹង បើសិន ។

សឿន ៖ ហ្នឹងអាបើសិននាងឯងពិចារណាមើល ម៉េចចុះឃើញចាស់ដើរផុតហើយទៅយកខ្ញុំទៅសម្លាប់ចោលមិនដឹង ។

ធានី ៖ អត់អីទេ ចឹងលោកតាចៅសុំថតជាសម្លេងក៏ដូចជាថតជារូបថតអីបានអត់?

សឿន ៖ ទេ! រូបថតមិនទាន់មកផង រូបថតគេឡើងយកទៅ ។

ធានី ៖ អត់ទេ ខ្ញុំសុំថតឥឡូវ ខ្ញុំមានកាំម៉ារ៉ាថត សុំថតរូបលោកតានឹងបានអត់?

សឿន ៖ បាទ! ចុះថតទៅស្ដី ខ្ញុំឲ្យថតនេះ ។

ធានី ៖ ចឹងលោកតាមានអីចង់សួរខ្ញុំវិញទេ ឬក៏ចង់បន្ថែមអ្វីដែលខ្ញុំមិនបានសួរ?

សឿន ៖ បាទ! សួរនេះសួរទៅចេះដែលខ្ញុំសព្វថ្ងៃវាចាស់ហើយរោគាណា បើកើតឫសដូងបាត មើលនេះសុទ្ធតែថ្នាំស្ពង់ថ្នាំអី ក្រែងពេទ្យអីចេះចាក់ចេះអី ។

ធានី ៖ អត់ផងលោកតា ពួកខ្ញុំខាងមជ្ឈមណ្ឌលឯកសារកម្ពុជាលោកតា ពួកខ្ញុំខាងអង្គការក្រៅរដ្ឋាភិបាល ហើយអង្គការហ្នឹងធ្វើការស្រាវជ្រាវទាក់ទងហ្នឹងសម័យខ្មែរក្រហម ។

សឿន ៖ ហៅអង្គការអី?

ធានី ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ។

សឿន ៖ មជ្ឈមណ្ឌល ។

ធានី ៖ ចា៎! កន្លែងឯកសារ ចា៎!កន្លែងពួកខ្ញុំគឺស្រាវជ្រាវតែរឿងប្រវត្តិសាស្រ្តសម័យខ្មែរក្រហមក៏ដូចជាមុនហ្នឹងតិច ក្រោយហ្នឹងតិចអីចឹងលោកតាណា៎ ។ ហើយដើម្បីទុកឲ្យក្មេងៗក្រោយបានដឹងពីរឿងរ៉ាវអស់ហ្នឹងផង ។

សឿន ៖ បាទ! ខ្ញុំខ្លាចអីនិយាយតាមដំណើរ ខ្លាចចុះ ខ្ញុំនិយាយបង្កាច់បង្កិន ខ្ញុំមិនមែននេះគេចេះឲ្យរំភើបចេះតែធ្វើចុះ នៅតែចេះមិនថាចុះដូចថានាងឯងថាខ្ញុំថាថតទៅវាមានទាស់អី ។

ធានី ៖ ចឹងលោកតាមានអីចង់បន្ថែមទៀតអត់ ចង់សួរនាំមកខ្ញុំវិញ ឬយ៉ាងម៉េចទេ?

សឿន ៖ អឺ! សួរអី សួរនាងឯង ។

ធានី ៖ ចា៎! មានអីចង់សួរថែមទៀត ឬក៏អត់ទេ?

សឿន ៖ អឺ! មានអី ចង់ខ្ញុំចង់រកអានេះតិច ព្រោះចាស់ហើយបត់ជើងបត់ដៃវាមិនមាន ចង់បានបន្ទន់

ធានី ៖ ពួកខ្ញុំមិនមែនខាងជួយខាងហ្នឹងទេតា ។

សឿន ៖ ក្រែងជួយ ក្រែងប៉ះទៅខាងនោះបាន វាមិនបានឯងចាប់មិនបានហ្នឹងគេ ។

ធានី ៖ ចឹងបន្ទន់អស់នេះ សុទ្ធតែមានគេជួយ?

សឿន ៖ បន្ទន់មានតិចណាស់បានប៉ុន្មាន គ្រប់តែក្រុម ម៉ាក្រុម២ ៗ ៣ខ្ទះ ។

ធានី ៖ ថឹងអរគុណលោកតាច្រើនដែលបានផ្ដល់បទសម្ភាសន៍ ។

«ចប់»